PESTECH

# ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

# របាយការណ៍ប្រចាំត្រីមាស

## ត្រីមាសទី ៣ សម្រាប់ឆ្នាំហិរញ្ញវត្ថុ

## ដែលបានបញ្ចប់នៅ

## ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

PESTECH

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ត្រីមាសទី៣ ឆ្នាំ ២០២៣ (លានរៀល) | ឆ្នាំ ២០២២ (លានរៀល) | ឆ្នាំ ២០២១ (លានរៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១ ២០៣ ០០៥ | ១ ២០២ ២៨២ | ១ ១៦៦ ៨៨២ |
| បំណុលសរុប | | ១ ១០៥ ៩០២ | ១ ០៩២ ២៦៦ | ១ ០៧២ ៩៨៥ |
| មូលធនសរុប | | ៩៧ ១០៣ | ១១០ ០១៦ | ៩៣ ៨៩៧ |
| **ចំណេញ/ (ខាត)** | | **ត្រីមាសទី៣ ឆ្នាំ ២០២៣ (លានរៀល)** | **ត្រីមាសទី៣ ឆ្នាំ ២០២២ (លានរៀល)** | **ត្រីមាសទី៣ ឆ្នាំ ២០២១ (លានរៀល)** |
| ចំណូលសរុប | | ១៩ ១៦០ | ៥៥ ២៩០ | ៥២ ៥៦៤ |
| (ខាត)/ចំណេញមុនបង់ពន្ធ | | (៤ ៦១០) | ១ ៧២៤ | ៣ ៧១៤ |
| ចំណេញប្រតិបត្តិការ | | ៥ ១៦៣ | ៦ ៤៤៥ | ៨ ០១៧ |
| (ខាត)/ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | (៥ ២៩០) | ៩៣៦ | ២ ២២០ |
| ចំណេញ/(ខាត)សរុបលម្អិត | | (៧ ៩៩៦) | ៧ ៨២៨ | ៦ ០៣៥ |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទី៣ ឆ្នាំ ២០២៣** | **ឆ្នាំ ២០២២** | **ឆ្នាំ ២០២១** |
| អនុបាតសាធនភាព | | (១,០៣%) | ១,៦៨% | ២,៤០% |
| អនុបាតសាធនភាព (ប្រាក់កម្ចីទូទៅ) * | | (៦,៤៣%) | ១៥,៩៥% | ៤៩,៩៣% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៩៥ | ០,៩៣ | ០,៩០ |
| | អនុបាតចរន្តលឿន | ០,៩៣ | ០,៩២ | ០,៨៨ |
| | | **ត្រីមាសទី៣ ឆ្នាំ ២០២៣** | **ត្រីមាសទី៣ ឆ្នាំ ២០២២** | **ត្រីមាសទី៣ ឆ្នាំ ២០២១** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | (០,៤៤%) | ០,០៧% | ០,២១% |
| | អនុបាតចំណេញធៀបនឹងមូលធន | (៥,៤៥%) | ០,៨៦% | ២,៥៦% |
| | អនុបាតគម្លាតចំណេញដុល | ៤៩,៤០% | ១៨,៨៤% | ២១,១៥% |
| | អនុបាតគម្លាតចំណេញភាព | (២៧,៦១%) | ១,៦៩% | ៤,២២% |
| | ចំណេញក្នុងមួយឯកតាមូលបត្រ កម្មសិទ្ធិ(ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) (រៀល) | (៧០,៥៩) | ១២,៤៩ | ២៩,៩៨ |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | ០,៤២ | ០,៨៥ | ១,៤២ |

PESTECH

* កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមិនរាប់បញ្ចូលលក្ខខណ្ឌកម្ចីរយៈពេលវែង ដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គីសនីកម្ពុជា(EDC)។ កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមានចំនួន ៦៥ ៤១១ លានរៀល (ឆ្នាំ ២០២២៖ ៤៣ ៨៨១ លានរៀល) និង កម្ចីរយៈពេលវែង មានចំនួន ៣៤២ ៨៣៥ លានរៀល គិតត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២៣ (ឆ្នាំ ២០២២៖ ៣៧២ ៦៩២ លានរៀល) ។

# សមាសភាពក្រុមប្រឹក្សាភិបាល



PESTECH

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះភាគហ៊ុនិក

សម្ព័ន្ធក្រុមហ៊ុនមានកិត្តិយសបង្ហាញជូននូវលទ្ធផលហិរញ្ញវត្ថុសម្រាប់ត្រីមាសទីបី (៣) ("Q៣" ឬ ត្រីមាស) នៃឆ្នាំហិរញ្ញវត្ថុ ("FY") ២០២៣។ ជាអកុសល ឱនភាពសារពើពន្ធបន្ទាប់ពីលទ្ធផលពន្ធដារនៅតែបន្តមាន ដោយសារសម្ព័ន្ធក្រុមហ៊ុនបានអត់ធន់នឹងស្ថានភាពទីផ្សារមិនអំណោយផល ដែលប៉ះពាល់ដល់ប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន។

ការដំឡើងការប្រាក់ឥតឈប់ឈរ រួមទាំងការគំរាមកំហែងអតិផរណាដែលខិតជិតមកដល់ បាននាំមកនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សម្ព័ន្ធក្រុមហ៊ុន ដែលបណ្តាលឲ្យក្រុមហ៊ុនចុះខ្សោយទាំងផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការផងដែរ។

ប្រាក់ចំណូលសរុបត្រូវបានកត់ត្រាត្រឹមចំនួន ១៩ ១៦០ ពាន់លានរៀលក្នុងកំឡុងត្រីមាស បើធៀបទៅនឹង ៥៥ ២៩០ ពាន់លានរៀល ក្នុងត្រីមាសដដែលសម្រាប់ការត្រួតពិនិត្យក្នុងឆ្នាំហិរញ្ញវត្ថុ ២០២២។ យ៉ាងណាមិញ ចំណូលអាចប្រៀបធៀបនឹងកំណត់ត្រានៃត្រីមាសមុនរបស់យើង។

ក្រុមហ៊ុនបានគ្រប់គ្រងក្នុងការចុះបញ្ជីប្រាក់ចំណេញប្រតិបត្តិការដែលមានចំនួន ៥ ១៦៣ ពាន់លានរៀល បើធៀបទៅនឹង ៦ ៤៤៥ ពាន់លានរៀល ក្នុងកំឡុងត្រីមាសទី៣ ឆ្នាំ២០២២។ គួរឲ្យសោកស្តាយ យើងបានបង្កើតការខាតបង់មុនពេលបង់ពន្ធ ("LBT") ដ៏ច្រើនជាងមុន ដែលមានចំនួន ៤ ៦១០ ពាន់លានរៀល ធៀបនឹងប្រាក់ចំណេញមុនពេលបង់ពន្ធ ("PBT") ដែលមានចំនួន ១ ៧២៤ ពាន់លានរៀល សម្រាប់ត្រីមាសដែលបានប្រៀបធៀបក្នុងឆ្នាំហិរញ្ញវត្ថុ ២០២២។ ដោយសារការចំណាយលើការខ្ចីប្រាក់កាន់តែខ្ពស់ យើងក៏បានរាយការណ៍ពីការខាតបង់ក្រោយបង់ពន្ធ ច្រើនជាងមុនដែលមានចំនួន ៥ ២៩០ ពាន់លានរៀល ធៀបនឹងប្រាក់ចំណេញក្រោយបង់ពន្ធ ("PAT") ចំនួន ០,៩៣៦ ពាន់លានរៀល ក្នុង Q3 ក្នុងឆ្នាំហិរញ្ញវត្ថុ ២០២២។

គណៈគ្រប់គ្រងបានកំពុងធ្វើការយ៉ាងសកម្មដើម្បីព្យាយាមឆ្ពោះទៅរកការផ្លាស់ប្តូរមួយ ហើយសង្ឃឹមថានឹងអាចផ្តល់នូវលទ្ធផលហិរញ្ញវត្ថុវិជ្ជមាននៅក្នុងត្រីមាសនាពេលអនាគត។ ក្រុមហ៊ុនតែងតែយកចិត្តទុកដាក់លើឱកាសទីផ្សារនៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធថាមពល ជាពិសេសនៅក្នុងប្រទេសកម្ពុជា។ និរន្តរភាពនៃការរីកចម្រើនសម្រាប់សម្ព័ន្ធក្រុមហ៊ុនអាស្រ័យលើសមត្ថភាពរបស់សម្ព័ន្ធក្រុមហ៊ុនក្នុងការទទួលបានគម្រោងថ្មីៗជាបន្តបន្ទាប់ ធានាបាននូវហិរញ្ញប្បទានដែលជាតម្រូវការ និងធានាថាក្រុមការងារដែលទទួលបន្ទុកផ្នែកប្រតិបត្តិអាចអនុវត្តគម្រោងប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព។ ក្នុងន័យនេះដែរ យើងចង់ធានាដល់ភាគហ៊ុនិករបស់យើងថា សម្ព័ន្ធក្រុមហ៊ុនប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តក្នុងការរក្សាជំហររបស់យើងក្នុងនាមជាអ្នកចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលនៅក្នុងប្រទេសកម្ពុជា។

ជាថ្មីម្តងទៀត យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគហ៊ុនិក អតិថិជន អ្នកផ្គត់ផ្គង់ និងក្រុមការងារក្នុងប្រទេសកម្ពុជាតែងតែផ្តល់ការគាំទ្រឥតឈប់ឈរ ដែលជួយជម្រុញឲ្យក្រុមហ៊ុនឆ្ពោះទៅមុខ ទោះក្នុងកាលៈទេសៈណាក៏ដោយ។

អរគុណ

PAUL LIM PAY CHUAN

ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

PESTECH

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

ភាគហ៊ុនិកជាទីរាប់អាន

យើងបានឆ្លងកាត់ ០៣ នៃឆ្នាំហិរញ្ញវត្ថុ ២០២៣ ចំពេលមានកត្តាប្រយោលដែលមានបញ្ហាប្រឈម ជះឥទ្ធិពលដល់ការអនុវត្តគម្រោងរបស់យើង ជាហេតុបណ្តាលឲ្យមានការបន្ថយល្បឿនក្នុងការកសាងប្រាក់ចំណូលសម្រាប់ត្រីមាសដែលកំពុងស្ថិតក្រោមការត្រួតពិនិត្យនេះ។

ការចំណាយលើការខ្ចីប្រាក់កាន់តែខ្ពស់របស់យើង បណ្តាលឲ្យកាន់តែពិបាកក្នុងការទ្រទ្រង់សកម្មភាពប្រតិបត្តិការ និងបំពេញតាមកាលកំណត់របស់គម្រោង។ ទោះជាយ៉ាងណាក៏ដោយ វាក៏តម្រូវឲ្យយើងមានភាពឧស្សាហ៍ព្យាយាមបន្ថែមទៀតក្នុងការគ្រប់គ្រងការចំណាយ និងការបែងចែកធនធាន ដែលអាចនាំឲ្យមានប្រសិទ្ធភាពប្រតិបត្តិការកាន់តែប្រសើរឡើង។

ផ្នែកប្រតិបត្តិគម្រោងបានសង្កេតឃើញការវិវត្តន៍មិនសូវរលូនជាមួយនឹងសកម្មភាពសំខាន់ៗដែលទាញចេញពីគម្រោងភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ រួមជាមួយនឹងគម្រោងខ្សែក្រោមដី ២៣០KV ដែលផ្តល់មូលនិធិដោយ JICA ។ យើងនឹងអាចផ្តល់នូវការអនុវត្តគម្រោងក្នុងកម្រិតដ៏ខ្ពស់មួយ បន្ទាប់ពីយើងបានបញ្ចប់ការរៀបចំហិរញ្ញប្បទានគម្រោងសម្រាប់គម្រោងទាំងពីរនាពេលខាងមុខនេះ។

ជាមួយគ្នានេះដែរ ក្រុមការងាររបស់យើងនឹងពឹងផ្អែកលើ គ្រឿងចក្រដែលបំពាក់បានយ៉ាងល្អជាមួយនិងបទពិសោធន៍ជាច្រើនក្នុងការរចនា វិស្វកម្ម និងការអនុវត្ត លើគ្រឿងបរិក្ខារប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនៅលើដំបូល ដើម្បីនាំ EPCC និងសេវាគ្រប់គ្រងគម្រោង ឆ្ពោះទៅរកការរីកចម្រើនផ្នែកទីផ្សារថាមពលកកើតឡើងវិញនៅប្រទេសកម្ពុជា។ ដោយហេតុនេះ យើងនឹងបន្តរួមចំណែកក្នុងការលើកកម្ពស់ការអភិវឌ្ឍថាមពលប្រកបដោយនិរន្តរភាព ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការធ្វើសមាហរណកម្មធនធានថាមពលកកើតឡើងវិញយ៉ាងសកម្មទៅក្នុងល្បាយថាមពលរបស់ខ្លួន។

សម្ព័ន្ធក្រុមហ៊ុននៅតែមានគំនិតសុទិដ្ឋិនិយមចំពោះលទ្ធផលការងារនាពេលអនាគតរបស់ខ្លួន ដោយផ្តោតលើគម្រោងផ្តល់ចំណូលរហ័សដោយសមហេតុផល ជាមួយនឹងការចំណាយដើមទុនតិចតួចបំផុត។ យើងខិតខំផ្តល់នូវអ្វីដែលល្អបំផុត និងបង្ហាញពីការដឹងគុណរបស់យើងចំពោះភាគហ៊ុនិក អតិថិជន អ្នកផ្គត់ផ្គង់ និងក្រុមការងាររបស់យើង សម្រាប់ទំនុកចិត្ត និងការគាំទ្រដើម្បីការអភិវឌ្ឍន៍របស់យើង។

សូមអរគុណ

PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

HAN FATT JUAN

**នាយកប្រតិបត្តិ**

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

PESTECH

## មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ....................i

សមាសភាពក្រុមប្រឹក្សាភិបាល ....................ii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ....................iii

សេចក្តីថ្លែងប្រធាននាយកប្រតិបត្តិ ....................iv

**ផ្នែកទី១៖ ព័ត៌មានទូទៅនៃក្រុមហ៊ុន ចុះបញ្ជី**

ក. អត្តសញ្ញាណក្រុមហ៊ុនចុះបញ្ជី
ខ. សកម្មភាពអាជីវកម្ម
គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី២៖ ព័ត៌មានពីលទ្ធផលប្រតិបត្តិការអាជីវកម្ម**

ក. លទ្ធផលប្រតិបត្តិការជីវកម្ម
ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្រឡើងវិញដោយសវនកឯករាជ្យ**

**ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង**

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ
ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ
គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល
ឃ. ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ
ង. ផលប៉ះពាល់នៃអតិផរណា
ច. សេដ្ឋកិច្ច សារពើពន្ធ គោលនយោបាយរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

**ផ្នែកទី៥៖ ព័ត៌មានសំខាន់ៗដ៏ទៃផ្សេងទៀតសម្រាប់ការការពារវិនិយោគិន**

ហត្ថលេខារបស់អភិបាលនៃក្រុមហ៊ុនចុះបញ្ជី

PESTECH

## ផ្នែកទី១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | **ផេសថិក (ខេមបូឌា) ម.ក** |
| ជាអក្សរឡាតាំង | **PESTECH (CAMBODIA) PLC** |
| លេខកូដស្តង់ដារ | KH១០០០១៥០០០៩ |
| និមិត្តសញ្ញា | ផថខ |
| អាសយដ្ឋាន | អគារលេខ ៣៥ ជាន់ទី១០ ផ្លូវម៉ៅសេទុង ភូមិ៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ៨៨២ ១០៥ |
| លេខទូរសារ | +៨៥៥ ២៣ ៨៨២ ១០៦ |
| គេហទំព័រ | www.pestech.com.kh |
| អ៊ីមែល៖ | info@pestech.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០០៩៥៧ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ៣២៦ ប្រក.ជនស.អសណ ចេញដោយ ជនស ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៧១/២០ គ.ម.គ/ស.ស.រ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជានិយ័តករមូលបត្រកម្ពុជា "នមក") |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Paul Lim Pay Chuan |

### ខ. ប្រភេទអាជីវកម្ម

ផថខ បានរួមចំណែកជាចម្បងក្នុងការផ្តល់ វិស័យវិស្វកម្ម និងដំណោះស្រាយបច្ចេកទេសនៃប្រព័ន្ធអគ្គីសនីដ៏ទូលំទូលាយសម្រាប់៖

- ការរចនាប្លង់ លទ្ធកម្ម សាងសង់ តម្លើង និងការដាក់ឱ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គីសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គីសនីក្រោមដីសម្រាប់បញ្ជូន និងចែកចាយអគ្គីសនីផងដែរ
- កិច្ចដំណើរការ និងការថែទាំ ("O&M") ខ្សែបញ្ជូនអគ្គីសនី និងអនុស្ថានីយ៍ និង
- ការធ្វើពាណិជ្ជកម្ម បរិក្ខារប្រព័ន្ធអគ្គីសនី និងឧបករណ៍ ជាកម្មសិទ្ធិ និងមិនមែនជាកម្មសិទ្ធិ

### គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

មិនមានព្រឹត្តិការសំខាន់ប្រចាំត្រីមាសរំឡងពេលត្រួតពិនិត្យនោះទេ។

PESTECH

## ផ្នែកទី២៖ ព័ត៌មានអំពីលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម

### ក. លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គីសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាស ក្រោមការត្រួតពិនិត្យដែលមានទឹកប្រាក់ចំនួន ១១ ២២១ លានរៀល (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៥២ ០៧៣ លានរៀល) ដែលស្មើនឹងប្រមាណ ៥៨,៦% (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៩៤,២%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសកម្មភាពថែទាំ("O&M") ការកត់ត្រាប្រាក់ចំណូល មានទឹកប្រាក់ចំនួន ៧ ៩៣៩ លានរៀល ដែលស្មើនឹង ៤១,៤% នៃចំណូលសរុប (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៣ ២១៧ លានរៀល ឬ ៥,៨%)។

ផ្នែកចម្បង ដែលធ្វើអោយមានការកើនឡើងនេះគឺ បណ្តាលមកពីការផ្លាស់ប្តូរកិច្ចសន្យានៃគម្រោងប្រតិបត្តិការ និងសេវាថែទាំ ("O&M") នៅក្រុងព្រះសីហនុ។

ក្នុងកំឡុងត្រីមាសនេះ សម្ព័ន្ធក្រុមហ៊ុនបានទទួលស្គាល់ចំណូលហិរញ្ញប្បទានមានចំនួន ២ ៥២៦ លានរៀល (ត្រីមាសទីបី ឆ្នាំ ២០២២៖ ២ ៧៩៨ លានរៀល) សម្រាប់កិច្ចសន្យាដាក់លាក់ជាមួយអតិថិជន ស្របតាមការអនុលោមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ១៥ ("CIFRS") ។ ចំណូលហិរញ្ញប្បទានគឺជាផ្នែកមួយនៃប្រាក់ចំណូលសរុបរបស់យើងនៅក្នុងសម្ព័ន្ធ។

### ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទីបី ឆ្នាំ២០២៣ | | ត្រីមាសទីបី ឆ្នាំ២០២២ | | ត្រីមាសទីបី ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ("EPCC") កិច្ចសន្យាសម្រាប់អគ្គីសនី និងអនុស្ថានីយ៍ | ១១ ២២១ | ៥៨,៦ | ៥២ ០៧៣ | ៩៤,២ | ៤៩ ៣៧៨ | ៩៣,៩ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ៧ ៩៣៩ | ៤១,៤ | ៣ ២១៧ | ៥,៥ | ៣ ១៨៦ | ៦,១ |
| | **ប្រាក់ចំណូលសរុប** | **១៩ ១៦០** | **១០០,០** | **៥៥ ២៩០** | **១០០,០** | **៥២ ៥៦៤** | **១០០,០** |

| ល.រ | ប្រភពចំណូលកិច្ចសន្យា | ត្រីមាសទីបី ឆ្នាំ ២០២៣ | | ត្រីមាសទីបី ឆ្នាំ ២០២២ | | ត្រីមាសទីបី ឆ្នាំ ២០២១ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ប្រាក់ចំណូល | ១៩ ១៦០ | ៨៨,៤ | ៥៥ ២៩០ | ៩៥,២ | ៥២ ៥៦៤ | ៩៧,៦ |
| ២ | ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យា | ២ ៥២៦ | ១១,៦ | ២ ៧៩៨ | ៤,៨ | ១ ២៨៦ | ២,៤ |
| | **ប្រាក់ចំណូលកិច្ចសន្យាសរុប** | **២១ ៦៨៦** | **១០០,០** | **៥៨ ០៨៨** | **១០០,០** | **៥៣ ៨៥០** | **១០០,០** |

PESTECH

## ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុពិនិត្យដោយសវនករខាងក្រៅ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយត្រូវបានធ្វើការត្រួតពិនិត្រឡើងវិញរួចរាល់ហើយដោយសវនករឯករាជ្យ។

## ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង ("MD&A")

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ បានកត់ត្រាត្រឹម ១៩ ១៦០ លានរៀល ដោយថយចុះចំនួន ៣៦ ១៣០ លានរៀល ឬ ៦៥,៣% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនដែលបានកត់ត្រាចំនួនត្រឹម ៥៥ ២៩០ លានរៀល។ បម្រែបម្រួលនៃប្រាក់ចំណូលបានឆ្លុះបញ្ចាំងពីវឌ្ឍភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នដែលស្ថិតនៅក្រោមការត្រួតពិនិត្យ គឺបណ្តាលមកពីវឌ្ឍនភាពនៃគម្រោងទាបជាងដែលត្រូវបានទទួលស្គាល់ដោយគម្រោងព្រំដែនឡាវ និងគម្រោងតាកែបើប្រៀបធៀបនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

### ២. ការវិភាគចំណូលតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គីសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាសក្រោមការត្រួតពិនិត្យឡើងវិញ ដែលមានទឹកប្រាក់ចំនួន ១១ ២២១ លានរៀល (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៥២ ០៧៣ លានរៀល) ដែលស្មើនឹងប្រមាណ ៥៨,៦% (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៩៤,២%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសកម្មភាពថែទាំ("O&M") ការកត់ត្រាប្រាក់ចំណូលមានទឹកប្រាក់ចំនួន ៧ ៩៣៩ លានរៀល ដែលស្មើនឹង ៤១,៤% នៃចំណូលសរុប (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៣ ២១៧ លានរៀល ឬ ៥,៨%)។

ផ្នែកចម្បង ដែលធ្វើអោយមានការកើនឡើងនេះ គឺបណ្តាលមកពីការផ្លាស់ប្តូរកិច្ចសន្យានៃគម្រោងប្រតិបត្តិ និងសេវាថែទាំ ("O&M") នៅក្រុងព្រះសីហនុ។

### ៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ៤៩,៤% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនមានចំនួន ១៨,៩% ដោយកើនឡើងចំនួន ៣០,៥%។ ចំណេញដុលខ្ពស់ជាងក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ គឺបណ្តាលមកពីការផ្លាស់ប្តូរកិច្ចសន្យានៃគម្រោងប្រតិបត្តិការនិងសេវាថែទាំ("O&M") នៅក្រុងព្រះសីហនុ។

### ៤. ការវិភាគចំណេញមុនបង់ពន្ធ

ខាតមុនបង់ពន្ធសម្រាប់ត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ៤ ៦១០ លានរៀល បើប្រៀបធៀបទៅនឹងការចំណេញមុនពេលបង់ពន្ធដែលមានចំនួន ១ ៧២៤ លានរៀលក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះចំនួន ៦ ៣៣៤ លានរៀល ឬ ៣៦៧,៤% ។ ខាតមុនបង់ពន្ធជាកត្តាចម្បងដែលបានមកពីការទទួលស្គាល់ប្រាក់ចំណូលទាបសម្រាប់ត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន និងថ្លៃដើមហិរញ្ញប្បទានខ្ពស់ដោយសារការដំឡើងអត្រាការប្រាក់។

PESTECH

## ៥. ការវិភាគ(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ

ការខាតក្រោយដកពន្ធនៃត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញមានចំនួនត្រឹម ៥ ២៩០ លានរៀល បើប្រៀបធៀបទៅនឹងចំណេញក្រោយដកពន្ធមានចំនួន ៩៣៦ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនដោយថយចុះមានចំនួន ៦ ២២៦ លានរៀល ឬ ៦៦៥,២%។

## ខ. កត្តាសំខាន់ដែលជះឥទ្ធិពលលើប្រាក់ចំណេញ

អំឡុងពេលក្រោមការត្រួតពិនិត្យឡើងវិញនេះ មិនមានកត្តាសំខាន់ៗណាមួយដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់ប្រតិបត្តិការចំពោះសម្ព័ន្ធក្រុមហ៊ុនឡើយ។

## គ. ការប្រែប្រួលសំខាន់ៗនៃការលក់ និងប្រាក់ចំណេញ

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២៣ បានកត់ត្រាត្រឹម ១៩ ១៦០ លានរៀល ដោយថយចុះចំនួន ៣៦ ១៣០ លានរៀល ឬ ៦៥,៣% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន បានកត់ត្រាត្រឹម ៥៥ ២៩០ លានរៀល ។ បម្រែបម្រួលនៃចំណូលសរុបបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញគឺបណ្តាលមកពីទទួលស្គាល់ដោយគម្រោងព្រំដែនឡាវ និងគម្រោងតាកែ បើប្រៀបធៀបនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងតម្លៃទំនិញ

ការកើនឡើងនៃអត្រាLIBOR នាពេលថ្មីៗនេះបានមកពីការកើនឡើងនៃចំណាយហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន។ ទោះបីជាមានការកើនឡើងនៃអត្រា LIBOR ក៏ដោយក៏សម្ព័ន្ធក្រុមហ៊ុនបានចុះកិច្ចសន្យាលើគម្លាតអត្រាការប្រាក់នៃកិច្ចសន្យាបញ្ចាំ ផលប៉ះពាល់របស់សម្ព័ន្ធក្រុមហ៊ុនពីហានិភ័យអត្រាការប្រាក់លើឥណទានមានការកំណត់ដែលអនុញ្ញាតអោយសម្ព័ន្ធក្រុមហ៊ុនបង្កើនប្រាក់កម្ចីក្នុងអត្រាទីផ្សារប្តូរទៅជាអត្រាថេរ។ ក្រៅពីការលើកឡើងខាងលើនេះ ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងការឡើងចុះនៃតម្លៃទំនិញនោះទេ។

## ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មរបស់យើង គឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ២៩% នៃចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជា មានចំនួន ៣,០% ( គិតត្រឹមថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០២៣ ប្រភព៖ ADB pegs :កំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ ២០២៣ មាន ៥,៥ % ) ដែលបានបង្កផលប៉ះពាល់ប្រហែល ០,៨៦% ប៉ុណ្ណោះ ចំពោះប្រាក់ចំណេញរបស់យើង ។ ក្រៅពីការលើកឡើងខាងលើនេះ ពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀត ដែលបណ្តាលមកពីអតិផរណានោះទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ រូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុនៅក្នុងអំឡុងឆ្នាំនេះនោះទេ។

## ផ្នែកទី ៥៖ ព័ត៌មានសំខាន់ៗដទៃទៀតសម្រាប់ការការពារវិនិយោគិន

ពុំមានព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន។

PESTECH

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

(ត្រូវចុះហត្ថលេខាដោយ ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលយ៉ាងតិច ២ នាក់)

ថ្ងៃអង្គារ ៤ កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ពស ២៥៦៧

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

បានអាន និងឯកភាព

**ហត្ថលេខា**

PESTECH (CAMBODIA) PLC

KINGDOM OF CAMBODIA

**PAUL LIM PAY CHUAN**

**ប្រធានក្រុមប្រឹក្សាភិបាល**